# ស្ថានីយផូស៊ីលឈើ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង

ផូស៊ីលឈើ (Petrified Wood) បានរកឃើញនៅសងខាងទន្លេមេគង្គ ក្នុងភូមិសាស្ត្រស្រុកសៀមបូក ខេត្តស្ទឹងត្រែងសងខាងដងទន្លេមេគង្គ។ តាមរយៈផែនទីភូគព្ភសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ស្ថានភាពដីនៃតំបន់នេះមានអក្សរសំគាល់ T3-J2ss[១] ដែលជាតំបន់នៃពពួកសិលាចាក់បង្គរ មានថ្មភក់ក្រហម ដីឥដ្ឋជាដើម ដែលស្ថិតក្នុងចុងសម័យកាល Triassic (២២៨លានឆ្នាំ) និងពាក់កណ្តាលសម័យកាល Jurassic (១៦១លានឆ្នាំ)។[២] ទីតាំងមួយចំនួនទៀតដែលស្ថិតនៅតាមកោះ ដូចជាកោះស្រឡៅ កោះព្រះ ក្នុងផែនទីមានអក្សរសំគាល់ Q2a ជាទីតាំងដែលមានដីចាក់បង្គរ ដែលស្ថិតក្នុងសម័យកាល Quaternary (អាយុកាលប្រមាណ២លានឆ្នាំនិងបន្តមកបច្ចុប្បន្ន)។ ប៉ុន្តែអាយុកាលនៃតំបន់នេះមានភាពខុសគ្នា គឺវាបានបង្ហាញអំពីការចាក់បង្គនៃឥទ្ធិពលរបស់ទន្លេមេគង្គមកលើតំបន់កោះទាំងនោះ។ ក្រុមការងារសិក្សាផូស៊ីលនៃនាយកដ្ឋានតំបន់បេតិកភណ្ឌអគ្គសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន បានទៅដល់ទីតាំងនោះកាលពីឆ្នាំ២០១៩។

ផូស៊ីលឈើភាគច្រើនបានរកឃើញនៅក្នុងតំបន់កោះព្រះ និងសងខាងដងទន្លេមេគង្គដោយ។ តាមរយៈប្រជាជនស្ថិតនៅទីតាំងភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក (រូបលេខ២) បានឱ្យដឹងថា មានគគីរថ្មជាច្រើនបានលេចចេញពីដី និងខ្លះកប់ក្នុងដីប្រមាណ១ម៉ែត្រ និងខ្លះទៀតក៏បានលេចចេញមកតាមច្រាំងនៃទន្លេមេគង្គផងដែរ។ តាមរយៈផូស៊ីលឈើដែលអ្នកស្រុកប្រមូលបាន គឺមានប្រភេទខុសៗគ្នា (រូបលេខ៣)។ ក្នុងភូមិសាស្ត្រដដែល យើងក៏បានប្រទះឃើញផូស៊ីលឈើស្ថិតក្នុងសាលាបឋមសិក្សាមួយនៅចំងាយប្រមាណ១គីឡូម៉ែត្រពីដងទន្លេមេគង្គ ដែលលេចចេញក្នុងពេលដែលគេឈូសឆាយធ្វើជាតារាងបាល់របស់សាលា (រូបលេខ៤)។ ផូស៊ីលឈើទាំងនេះស្ថិតនៅក្នុងស្រទាប់ដីឥដ្ឋ លាយឡំជាមួយគ្រួសអាចម៍ផ្កាយជាច្រើន ដែលបង្ហាញថាកាលពីអតីតាលក្នុងពេលណាមួយមានការហូរច្រោះខ្លាំង ដោយទឹកបាននាំមកនៅពពួកគ្រួសចាក់បង្គគ្របដណ្តប់

---

[១] 2010, General Department of Mineral Resource, Geological Map of Cambodia

[២] 2007, International Commission on Stratigraphy

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

*លើដើមឈើ អាចក្នុងរយៈពេលរាប់ម៉ឺន សែនឬលានឆ្នាំ ទើបធ្វើឱ្យដើមឈើបានក្លាយទៅជាថ្ម (រូបលេខ៥)។*

*ចំពោះទីតាំងរកផូស៊ីលឈើមួយទៀត ដែលស្ថិតនៅតាមផ្លូវធ្វើដំណើរឆ្លងកាត់កោះព្រះ ដោយក្រុមការងារបានជួបប្រទះផូស៊ីលឈើជាច្រើននក្នុងជម្រៅប្រមាណ១ម៉ែត្រ។ ហើយពួកនេះ គឺស្ថិតនៅក្នុងស្រទាប់ដីឥដ្ឋ និងមានស្រទាប់គ្រួសអាចម៍ផ្កាយនៅពីលើដូចគ្នា (រូបលេខ៦)។*

*ដោយឡែកទីតាំងឆ្លងពីកោះព្រះទៅកាន់ត្រោយម្ខាង នៃទន្លេមេគង្គ ស្ថិតនៅក្នុងស្រុកសៀមបូក ក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ ភូមិសាស្ត្រខេត្តស្ទឹងត្រែង។ ក្រុមការងារបានចុះពិនិត្យក្នុងទីតាំងមួយ មានចំងាយប្រមាណ៧គីឡូម៉ែត្រពីដងទន្លេមេគង្គ ផូស៊ីលឈើមួយចំនួនបានលេចចេញនៅក្នុងអូរដែលមានជម្រៅប្រមាន២ម៉ែត្រ (រូបលេខ៧-៨)។ យើងបានបន្តដំណើរតាមដងទន្លេមេគង្គរហូតដល់ក្បែរព្រំប្រទល់ខេត្តក្រចេះ ក៏បានជួបបំណែកផូស៊ីលឈើតូចៗនៅតាមផ្លូវផងដែរ។*

*តាមរយៈកស្តុតាងនៃទីតាំងដែលរៀបរាប់ខាងលើ យើងឃើញថាបរិវេណនៃផូស៊ីលឈើស្រុកសៀមបូក បានលាតសន្ធឹងប្រមាណ៣០គីឡូម៉ែត្រ នៅតាមកោះមួយចំនួន និងសងខាងដងទន្លេមេគង្គ និងអាចលាតសន្ធឹងទៅកាន់ខេត្តក្រចេះផងដែរ។ បាតុភូតនេះប្រហែលជាកើតមានក្នុងពេលវេលាមួយដែលមានទឹកហូរខ្លាំង ចាក់គ្របទៅលើរុក្ខជាតិដែលតំបន់ទាំងនោះជាព្រៃកាលពីបុរាណ។ ចំពោះអាយុកាលយើងមិនទាន់ដឹងច្បាស់នៅឡើយទេ វាអាចស្ថិតនៅចន្លោះរវាងសម័យកាល* Jurassic *មកកាន់សម័យកាល* Quaternary *(អាយុកាលប្រមាណ២លានឆ្នាំ)។ ប្រភេទដែលឃើញនៅតំបន់នេះមានលក្ខណៈខុសពីប្រភេទផូស៊ីលដើមឈើដែលឃើញនៅក្នុងភូមិសាស្ត្រស្រុកលំផាត់ ខេត្តរតនគិរី ។[៣] តែពួកនេះមានលក្ខណៈប្រហាក់ប្រហែលនិងផូស៊ីលដើមឈើដែលរកឃើញនៅភ្នំគូលែន។[៤] យើងសង្ឃឹមថានឹងអាចមានការសិក្សាស្រាវជ្រាវជាបន្តទៀតនាពេលអនាគត៕*

---

[៣] បុរាណវិទ្យា - AMS Khmer Civilization

[៤] បុរាណវិទ្យា - AMS Khmer Civilization

*អត្ថបទដោយ៖ លឹម វណ្ណចន្ទ*




រូបលេខ១



រូបលេខ២

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ៣



រូបលេខ៤

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបលេខ២៥



រូបលេខ២៦

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ២៧



រូបលេខ២៨

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ